# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)
# គម្រោងបញ្ចប់ផែនការ
# កំណែលើកទី៧
# ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥


**សេចក្តីសង្ខេប** ...... 2

I. **សេចក្តីផ្តើម** ...... 3

II. **វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស** ...... 6

III. **ផែនការបញ្ចប់ការស៊ើបអង្កេត** ...... 7

IV. **ផែនការបញ្ចប់សវនាការ** ...... 11

  ក. សំណុំរឿង០០២/០២ ...... 12

  ខ. បទចោទដែលនៅសេសសល់/ការចោទប្រកាន់តាមអង្គហេតុក្នុងសំណុំរឿង០០២ ...... 14

  គ. សំណុំរឿង០០៣ និង សំណុំរឿង០០៤ ...... 14

V. **ផែនការបញ្ចប់បណ្តឹងសាទុក្ខ** ...... 14

  ក. សំណុំរឿង០០២/០១ ...... 15

  ខ. សំណុំរឿង ០០២/០២ ...... 16

VI. **សេចក្តីសន្និដ្ឋាន** ...... 17


ឧបសម្ព័ន្ធ៖ តារាងកំណត់ពេលវេលាតាមការគ្រោងទុកសម្រាប់ការបញ្ចប់ផែនការ ដែលរួមមានគ្រោងការសំខាន់ៗ។

## សេចក្តីសង្ខេប

គម្រោងបញ្ចប់ផែនការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) បានរៀបចំឡើងដំបូងនៅខែមីនា ឆ្នាំ២០១៤ ដោយឆ្លងកាត់ការពិគ្រោះពិភាក្សាយោបល់ពីសំណាក់ការិយាល័យរដ្ឋបាល ជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះ សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ទាក់ទិននឹងការទទួលខុសត្រូវរបស់ពួកគាត់។ នេះគឺជាបច្ចុប្បន្នភាពប្រចាំត្រីមាសទី៧ នៃគម្រោងបញ្ចប់ផែនការដែលផុតនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

ក្នុងអំឡុងពេលត្រីមាសចុងក្រោយ គម្រោងបន្ថែមមួយដែលត្រូវបានគ្រោងទុកសម្រាប់ឆ្នាំ២០១៥ ត្រូវបានសម្រេច ដោយការជូនដំណឹងបិទកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៥ ទាក់ទងនឹងជនត្រូវចោទ អ៊ឹម ចែម។

អង្គជំនុំជម្រះតុលាការកំពូលបានចាប់ផ្តើមសវនាការលើបណ្តឹងសាទុក្ខបន្ថែមទៀត ក្នុងសំណុំរឿង ០០២/០១ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥។ បន្ទាប់ពីការធ្វើពហិការដោយមេធាវីការពារក្តី នួន ជា អង្គជំនុំជម្រះបានបង្គាប់ឱ្យតែងតាំងមេធាវីប្រចាំការសម្រាប់ នួន ជា និង បានគ្រោងធ្វើសវនាការលើបណ្តឹងសាទុក្ខចុងក្រោយពីថ្ងៃទី១៦ ដល់ ១៨ ខែកុម្ភៈ ឆ្នាំ២០១៦។

នៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ សវនាការលើភ័ស្តុតាងបានរីកចម្រើនទៅមុខ ជាមួយនឹងការបន្តប្រធានបទសវនាការទីបី ពោលគឺ ការប្រព្រឹត្តិលើជនជាតិចាម និងវៀតណាម ដែលរួមបញ្ចូលការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ក្នុងចំណោមឧក្រិដ្ឋកម្មផ្សេងទៀត។ ដោយសារតែផលប៉ះពាល់រួមគ្នានៃការពហិការរបស់មេធាវីការពារក្តីក្នុងអំឡុងពេលត្រីមាសចុងក្រោយនៃឆ្នាំ២០១៤ ពេលវេលាដែលផ្តល់ឱ្យភាគីក្នុងការរៀបចំសម្រាប់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ក៏ដូចជាការលើកពេលរបស់តុលាការក្នុងគោលបំណងពិនិត្យឯកសារដែលបានដាក់បង្ហាញពីសំណុំរឿង ០០៣ និង ០០៤ វាមានភាពចាំបាច់ក្នុងការកែប្រែតារាងពេលវេលាដែលបានគ្រោងទុកនេះ សម្រាប់ការបិទបញ្ចប់សវនាការ សេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោល និងការចេញសាលក្រមក្នុងសំណុំរឿង ០០២/០២ រយៈពេលបីខែសម្រាប់ផែនការនីមួយៗខាងលើនេះ។ តារាងពេលវេលាសម្រាប់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ប្រសិនបើមាន ក៏ត្រូវបានបន្ថែមរយៈពេលបីខែទៀតផងដែរ។

ក៏មានការរីកចម្រើនច្រើនកើតមានក្នុងរយៈពេលត្រីមាសចុងក្រោយនេះ នៅក្នុងកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ ផងដែរ ដែលជនសង្ស័យចុងក្រោយក្នុងសំណុំរឿង០០៤ គឺ យឹម ទិត្យ ត្រូវបានចោទប្រកាន់ដោយផ្ទាល់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥។ មាស មុត ដែលត្រូវបានចោទប្រកាន់ដោយកំបាំងមុខក្នុងសំណុំរឿង ០០៣ ក្នុងខែមីនា ឆ្នាំ២០១៥ បានបង្ហាញខ្លួនផ្ទាល់សម្រាប់ការបង្ហាញខ្លួនលើកដំបូង ហើយត្រូវបានចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥។ ជាលទ្ធផល សេចក្តីសម្រេចពីមុន ដែលចោទប្រកាន់គាត់ដោយកំបាំងមុខនោះ បានក្លាយទៅជាមោឃៈ ហើយដីកាបង្គាប់ឱ្យនាំខ្លួនមុននោះត្រូវបានបដិសេធ។ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីជូនដំណឹងរួមគ្នាអំពីការបិទបញ្ចប់កិច្ចស៊ើបសួរ ក្នុងសំណុំរឿង ០០៤ ទាក់ទងនឹងជនត្រូវចោទ អ៊ឹម ចែម។ ការពិនិត្យស្ថានភាពនៃការស៊ើបអង្កេតដែលនៅសេសសល់ ក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលទទួលបានការតែងតាំងថ្មី ក្នុងអំឡុងពេលត្រីមាសទីបួន បានសន្និដ្ឋានថា តារាងពេលវេលាដែលបានគ្រោងទុកពីមុន ក្នុងកាលៈទេសៈនានា គឺមានសុទិដ្ឋិនិយមជ្រុលហួស។ ជាវិបាក តារាងពេលវេលាដែលបានគ្រោងទុកជារួមសម្រាប់សំណុំរឿង ០០៣ ត្រូវបានបន្ថែមរយៈពេលចំនួនបីខែ ហើយសំណុំរឿង ០០៤ ត្រូវបានបន្ថែមរយៈពេលចំនួនប្រាំមួយខែ ដើម្បីឆ្លុះបញ្ចាំងការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី។

ការពិពណ៌នាអំពីគម្រោងបញ្ចប់ផែនការនេះត្រូវបានធ្វើបច្ចុប្បន្នភាព ក្នុងគោលបំណងដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពនៃដំណើការនីតិវិធីតុលាការគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

## I. សេចក្តីផ្តើម

១. អង្គជំនុំជ្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) បានចាប់ផ្តើមដំណើរការរបស់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០០៦ និងបានដំណើរការពេញលេញបន្ទាប់ពីការអនុម័តវិធានផ្ទៃក្នុងនៅក្នុងខែមិថុនា ឆ្នាំ២០០៧។ អាណត្តិនៃអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីកាត់សេចក្តី “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩”[1]។ នៅក្នុងរបាយការណ៍មួយ ដែលបានដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិនៅខែមីនា ឆ្នាំ២០០៣ អគ្គលេខាធិការ ដំបូងឡើយបានបង្ហាញថា អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ មានរយៈពេលបីឆ្នាំ ដើម្បីបញ្ចប់ការជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលទាំងអស់ “នៅពេលដែលការិយាល័យរបស់សហព្រះរាជអាជ្ញា បានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន”[2]។ តារាងកំណត់ពេលវេលាត្រូវបានកែប្រែចាប់តាំងពីពេលនោះមក ហើយអគ្គលេខាធិការបានជូនដំណឹងជាផ្លូវការដល់មហាសន្និបាតអង្គការសហប្រជាជាតិនៅខែតុលា ឆ្នាំ២០១៣ ថា តារាងកំណត់ពេលវេលារបស់អង្គជំនុំជម្រះវិសាមញ្ញ “មានគម្រោងសកម្មភាពតុលាការរហូតដល់ឆ្នាំ២០១៨ និងអាចបន្តហួសពីពេលវេលាកំណត់នេះទៅទៀត”[3]។

២. គម្រោងបញ្ចប់ផែនការនេះបានបរិយាយយ៉ាងលម្អិតដោយ អ.វ.ត.ក. ក្នុងបរិបទនៃសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ A/RES/68/247B ដែលក្នុងចំណោមបញ្ហាផ្សេងៗទៀត បានកំណត់អាណត្តិរបស់ អ.វ.ត.ក. ឱ្យរៀបចំយុទ្ធសាស្ត្របញ្ចប់ ដោយមានផែនទីបង្ហាញផ្លូវច្បាស់លាស់មួយ[4]។ ឯកសារនេះធ្វើឡើងដោយ អ.វ.ត.ក. ដោយមានការពិគ្រោះយោបល់តាមរយៈ ការិយាល័យរដ្ឋបាលជាមួយចៅក្រមអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាអំពីការទទួលខុសត្រូវរបស់ពួកគេ។ អ.វ.ត.ក. គិតទុកជាមុនថា នៅពេលខាងមុខ ខ្លួននឹងធ្វើបច្ចុប្បន្នភាពផែនការបញ្ចប់នេះរៀងរាល់ត្រីមាស។ ឯកសារនេះគឺជាកំណែលើកទី៧ ប្រចាំត្រីមាសនៃគម្រោងបញ្ចប់ផែនការ ហើយបានបញ្ចូលនូវការកែតម្រូវដោយផ្អែកលើការវិវត្តនៃដំណើរការនីតិវិធីតាមផ្លូវតុលាការ ដែលកំពុងប្រព្រឹត្តទៅក្នុងរវាងថ្ងៃទី១ ខែតុលា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

៣. ឯកសារនេះផ្តោតជាពិសេសលើការវិវត្តនាពេលថ្មីៗនេះ នៅក្នុងសំណុំរឿងទាំងបី ដែលបច្ចុប្បន្នកំពុងស្ថិតនៅចំពោះមុខ អ.វ.ត.ក. និងផ្តល់នូវព័ត៌មានអំពីស្ថានភាពនៃរឿងក្តីទាំងនោះ ព្រមទាំងជំហាននានាដែលត្រូវបំពេញ មុនពេលកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការទាក់ទិននឹងសំណុំរឿងកំពុងរង់ចាំបច្ចុប្បន្ននៅចំពោះមុខ អ.វ.ត.ក. អាចនឹងបញ្ចប់ជាស្ថាពរតាមផ្លូវច្បាប់។ សហព្រះរាជអាជ្ញាបានថ្លែងជាសាធារណៈថា នឹងមិនមានសំណុំរឿងបន្ថែមទៀត បន្ទាប់ពីសំណុំរឿង ០០៣ និង ០០៤ នោះឡើយ[5]។ ដូច្នេះ បន្ទុករឿងក្តីបច្ចុប្បន្នគឺជាសំណុំរឿងសរុបដែលអង្គជំនុំជម្រះវិសាមញ្ញត្រូវដោះស្រាយ។

---

[1] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[2] របាយការណ៍របស់អគ្គលេខាធិការស្តីពីការជំនុំជម្រះខ្មែរក្រហម ឯកសារ A/57/769 កថាខណ្ឌ ៥៦។

[3] សំណើសុំឧបត្ថមធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឯកសារ A/68/532 កថាខណ្ឌ ៣៨។

[4] នៅក្នុងសេចក្តីសម្រេចដដែលនោះ មហាសន្និបាត អ.ស.ប. បានស្នើឲ្យមាន “ការពិនិត្យយ៉ាងម៉ត់ចត់ទៅលើការផ្តល់ហិរញ្ញប្បទានសម្រាប់ អ.វ.ត.ក នៅពេលអនាគតសម្រាប់ឆ្នាំ ២០១៥ និងឆ្នាំខាងមុខទៀត”។ សូមមើលសេចក្តីសម្រេចលេខ A/RES/68/247B ដែលអនុម័តដោយមហាសន្និបាត អ.ស.ប. នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៤៖ “កម្មវត្ថុពិសេសនានាទាក់ទិននឹងថវិកាសម្រាប់កម្មវិធីរយៈពេល២ឆ្នាំម្តង ២០១៤-២០១៥” ខ, I, កថាខណ្ឌទី៨។

[5] សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី - ការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីចំនួនពីរ ថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ២០០៩ (www.eccc.gov.kh/sites/default/files/media/ECCC_Act_Int Co Prosecutor 8 Sep_2009_(Eng).pdf)

៤. មកដល់ពេលនេះអង្គជំនុំជម្រះបានបំបែកបទចោទនៅក្នុងសំណុំរឿង ០០២ ទៅជាសវនាការតូចៗ ចំនួនពីរ។ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមនៅក្នុងសវនាការដំណាក់កាលទីមួយ ដែលអង្គជំនុំជម្រះវិសាមញ្ញកំណត់ឈ្មោះសំណុំរឿងថា សំណុំរឿង០០២/០១ នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន។ ជនជាប់ចោទពីរនាក់ទៀតនៅក្នុងរឿងក្ដី គឺ អៀង សារី និង អៀង ធីរិទ្ធ បានទទួលមរណភាពនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ និងថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥ ហេតុនេះហើយ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងពួកគេត្រូវបានរំលត់។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៧ និងត្រូវបានផ្ដន្ទាទោសម្នាក់ៗឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ ទាំង នួន ជា និង ខៀវ សំផន បានដាក់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០១។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាក៏បានដាក់បណ្ដឹងសាទុក្ខកម្រិតត្រឹមតែស្នើសុំ សេចក្ដីប្រកាសជាប្រយោជន៍ទៅលើការអនុវត្តទម្រង់ទូលាយបំផុតនៃសហឧក្រិដ្ឋកម្មរួមដែលហៅថា “JCE III” ជាទម្រង់ទទួលខុសត្រូវមួយនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។

ដំណើរការនីតិវិធីបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ កំពុងតែអនុវត្ត។ អង្គជំនុំជម្រះតុលាការកំពូលបានបើកសវនាការបណ្ដឹងសាទុក្ខដំបូងរបស់ខ្លួននៅថ្ងៃទី២, ៣ និង ៦ ខែកក្កដា ឆ្នាំ២០១៥ ហើយសវនាការបណ្ដឹងសារទុក្ខបន្ថែមទៀតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ ដោយបន្ទាប់មកការបិទបញ្ចប់គ្រោងធ្វើនៅខែកុម្ភៈ ឆ្នាំ២០១៦។ ការពន្យារពេលសវនាការលើបណ្ដឹងសាទុក្ខ ដែលផ្អែកលើកាលៈទេសៈដែលមិនអាចព្យាករបានដូចបានពន្យល់បន្ថែមក្នុងជំពូក V ខាងក្រោមនេះ មិនមានផលប៉ះពាល់លើតារាងពេលវេលាដែលបានគ្រោងទុកសម្រាប់ចេញសាលដីកាក្នុងសំណុំរឿង ០០២/០២ នោះទេ។

៦. ការជំនុំជម្រះទីពីរកំពុងដំណើរការក្នុងពេលបច្ចុប្បន្ននេះ ដែលអង្គជំនុំជម្រះវិសាមញ្ញដាក់ឈ្មោះថា សំណុំរឿង ០០២/០២ គឺផ្ដោតលើជម្រើសតំណាងបទចោទមួយចំនួនដែលនៅសល់ប្រឆាំងនឹងជនជាប់ចោទទាំងពីរនាក់ បទចោទទាំងនោះរួមមាន អំពើប្រល័យពូជសាសន៍លើក្រុមជាតិពន្ធចាមនិងវៀតណាម អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ ការប្រព្រឹត្តិលើពុទ្ធសាសនិក ការបោសសម្អាតផ្ទៃក្នុង និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលចោទប្រកាន់ថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខចំនួន៤ ការដ្ឋានចំនួន៣ និង ក្រុមមួយនៃសហករណ៍។ សវនាការលើភស្តុតាងក្នុងសំណុំរឿង ០០២/០២ បានចាប់ផ្ដើមនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ នៅត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ អង្គជំនុំជម្រះសាលាដំបូងបានស្ដាប់សក្ខីកម្មសាក្សីចំនួន ៥៦ នាក់ ដើមបណ្ដឹងរដ្ឋប្បវេណី ៣០ នាក់ និងអ្នកជំនាញម្នាក់។ ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនត្រូវបានស្ដាប់សក្ខីកម្មក្នុងអំឡុងពេលសវនាការដែលរៀបចំជាក់លាក់សម្រាប់ការស្ដាប់សក្ខីកម្មស្ដីពីការឈឺចាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅតាមសហករណ៍ និងការដ្ឋាន។ ដោយសារតែផលប៉ះពាល់រួមគ្នានៃការពហិការរបស់មេធាវីការពារក្ដីក្នុងអំឡុងពេលត្រីមាសចុងក្រោយនៃឆ្នាំ២០១៤ ពេលវេលាដែលផ្ដល់ឱ្យភាគីក្នុងការរៀបចំសម្រាប់កិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ក៏ដូចជាការលើកពេលរបស់តុលាការក្នុងគោលបំណងពិនិត្យឯកសារដែលបានដាក់បង្ហាញពីសំណុំរឿង ០០៣ និង ០០៤ វាមានភាពចាំបាច់ក្នុងការបន្ថែមពេលវេលាតារាងកំណត់ពេលវេលានៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ រយៈពេលបីខែ។ ការណ៍នេះត្រូវបានពន្យល់បន្ថែមទៀតនៅក្នុងជំពូក IV ខាងក្រោម។

---

។ សេចក្ដីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១២ (www.eccc.gov.kh/sites/default/files/media/ECCC%20OCP%205%20June%202012%20En.pdf) និងសេចក្ដីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងចំនួនរឿងក្ដីរបស់ អ.វ.ត.ក. ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ (http://www.eccc.gov.kh/en/articles/statement-international-co-prosecutor-regarding-eccc-caseload)។

៧. បច្ចុប្បន្ន សំណុំរឿង ០០៣ និង ០០៤ កំពុងតែស្ថិតក្នុងដំណាក់កាលស៊ើបសួរនៅឡើយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិកំពុងតែស៊ើបអង្កេតយ៉ាងសកម្មទៅលើសំណុំរឿងទាំងនេះ ដែលពាក់ព័ន្ធនឹងការចោទប្រកាន់ជនត្រូវចោទ ៣ នាក់ និង ជនសង្ស័យ ១ នាក់។ មានការបន្តរីកចម្រើនជាច្រើន ទៅលើសំណុំរឿងទាំងពីរនេះ នៅក្នុងអំឡុងត្រីមាសទី៣ ឆ្នាំ២០១៥។ នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៥ សហចៅក្រមអន្តរជាតិបានចោទប្រកាន់ យឹម ទិត្យ ដោយផ្ទាល់ក្នុងសំណុំរឿង ០០៤ និង មាស មុត ក្នុងសំណុំរឿង ០០៣។ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីជូនដំណឹងរួមគ្នា អំពីការបិទបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤ ទាក់ទងនឹងជនត្រូវចោទ អ៊ឹម ចែម។ បន្ទាប់ពីបានពិនិត្យមើលស្ថានភាពនៃការស៊ើបអង្កេតដែលនៅសេសសល់ ក្នុងសំណុំរឿង ០០៣ និង ០០៤ រួចមក សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលទើបទទួលបានការតែងតាំងថ្មី បានសន្និដ្ឋានថា តារាងកំណត់ពេលវេលាដែលបានប៉ាន់ស្មានពីមុន ក្នុងកាលៈទេសៈនានា គឺមានសុទិដ្ឋិនិយមជ្រុលហួស។ ដូចបានពន្យល់បន្ថែមក្នុងជំពូក III ខាងក្រោម តារាងកំណត់ពេលវេលាដែលបានគ្រោងទុកជារួមសម្រាប់សំណុំរឿង ០០៣ ត្រូវបានបន្ថែមរយៈពេលចំនួនបីខែ ហើយសំណុំរឿង ០០៤ ត្រូវបានបន្ថែមរយៈពេលចំនួនប្រាំមួយខែ។

៨. តាមរយៈការវិវត្តក្នុងត្រីមាសចុងក្រោយនេះ គម្រោងបញ្ចប់ផែនការរបស់អង្គជំនុំជម្រះវិសាមញ្ញមានគ្រោងការសំខាន់ចំនួន ១៧ សម្រាប់សំណុំរឿងចំនួនបី ដែលអង្គជំនុំជម្រះនានាបានទទួល។ គ្រោងការសំខាន់ដែលនៅសេសសល់នៅក្នុងសំណុំរឿង០០២ និង[6] ការព្យាករណ៍ ដែលបន្តពាក់ព័ន្ធគឺ៖

(i) ការបញ្ចប់សវនាការលើបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង០០២/០១ (ត្រីមាសទី១ ឆ្នាំ២០១៦)

(ii) ការចេញសាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ (ត្រីមាសទី២ ឆ្នាំ២០១៦)

(iii) ការបញ្ចប់សវនាការលើអង្គសេចក្តី ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី១ ឆ្នាំ២០១៧)

(iv) សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី១ ឆ្នាំ២០១៧)

(v) ការចេញសាលក្រមនៅក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី៤ ឆ្នាំ២០១៧)

(vi) ពេលវេលាកំណត់នៃការដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី១ ឆ្នាំ២០១៨) និង

(vii) ការចេញសាលដីកានៅក្នុងសំណុំរឿង០០២/០២ ប្រសិនបើមាន (ត្រីមាសទី៣ ឆ្នាំ២០១៩)។

៩. នៅក្នុងសំណុំរឿង ០០៣ និង ០០៤ គ្រោងការដាច់ដោយឡែក ត្រូវបានកំណត់សម្រាប់ដំណាក់កាលស៊ើបអង្កេតដែលនៅសេសសល់ ហើយក្នុងករណីមានការចោទប្រកាន់នោះ នឹងមានគ្រោងការបន្ថែមទៀតសម្រាប់ដំណាក់កាលជំនុំជម្រះ និងបណ្តឹងសាទុក្ខ[7]។ គ្រោងការសំខាន់សម្រាប់ដំណាក់កាលស៊ើបអង្កេតដែលបន្តនៅសេសសល់ គឺ៖

(viii) សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ (ត្រីមាសទី៣ ឆ្នាំ២០១៦)

(ix) សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤ (ត្រីមាសទី២ ឆ្នាំ២០១៥ និង/ឬ ត្រីមាសទី៤ ឆ្នាំ២០១៦ អាស្រ័យទៅលើការបំបែកកិច្ចនីតិវិធីណាមួយ)។

---

[6] នៅក្នុងករណីដែលសំណុំរឿង០០២ ត្រូវបានបំបែកបន្ថែមទៀតតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ទៅលើវិសាលភាពនៃសំណុំរឿង០០២/០២ ដែលរំពឹងថានឹងចេញនៅខែមេសា ឆ្នាំ២០១៤ វានឹងតម្រូវឲ្យមានសំណុំរឿង០០២/០៣។

[7] ដូចដែលកត់សម្គាល់ត្រង់កថាខណ្ឌទី៣៦ ខាងក្រោម ដោយសារស្ថានភាពនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន នៅពេលនេះយើងមិនអាចព្យាករនូវចំណុចពេលវេលាជាក់លាក់ ទាក់ទិននឹងគ្រោងការជំនុំជម្រះក្តីបានឡើយ។

(x) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ជាមួយនឹងសេចក្តីសម្រេចថាតើបញ្ជូនរឿងទៅជំនុំជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី៤ ឆ្នាំ២០១៦)។

(xi) ការចេញដីកាដំណោះស្រាយ១ (ច្រើន) ក្នុងសំណុំរឿង០០៤ ជាមួយនឹងសេចក្តីសម្រេចថាតើ ត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី (អាស្រ័យលើ ថាតើសំណុំរឿងនឹងត្រូវបំបែក ឬអត់ នៅត្រីមាសទី២ និងទី៤ ឆ្នាំ២០១៦ និង/ឬ ត្រីមាសទី២ ឆ្នាំ២០១៧)។

(xii) សេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីក្នុងសំណុំរឿងនោះ (ត្រីមាសទី២ ឆ្នាំ២០១៧)។ និង

(xiii) សេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ណាមួយ ប្រឆាំងនឹងដីកាដំណោះស្រាយមួយ(ច្រើន) ក្នុងសំណុំរឿង០០៤ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីក្នុងសំណុំរឿងនោះ (ត្រីមាសទី៤ ឆ្នាំ២០១៧)។

## II. វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស

១០. ដំណើរការប្រកបដោយប្រសិទ្ធភាពរបស់អង្គជំនុំជម្រះវិសាមញ្ញ កន្លងទៅត្រូវបានរំខានដោយអសន្តិសុខផ្នែកហិរញ្ញវត្ថុដែលចេះតែបន្តកើតមាន ដែលបណ្តាលឱ្យបុគ្គលិកចំនួនពីររូបបានបោះបង់ការងារក្នុងអំឡុងឆ្នាំ២០១៣ ព្រមទាំងបុគ្គលិកចេញចូលពីមុខតំណែងដោយមិនសមហេតុផល។ ការអនុម័តរបស់មហាសន្និបាតទៅលើឧបត្ថម្ភធនសម្រាប់ឆ្នាំប្រតិទិន ២០១៤ និង ២០១៥ សម្រាប់ភាគីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញ គឺជាវិធានការដ៏សំខាន់ដែលបានធ្វើឲ្យមានស្ថិរភាពដល់ស្ថានភាពថវិកា និងធ្វើឲ្យមានការផ្តោតមូលទៅលើការធ្វើឲ្យវិវត្តទៅមុខនៃអាណត្តិតុលាការ។ ទោះជាយ៉ាងណា ផ្នែកភាគីជាតិ ភាពលំបាកខាងលំហូរសាច់ប្រាក់បាននាំឱ្យមានការពន្យារជាងដែល១ៗក្នុងបើកប្រាក់ខែឱ្យបុគ្គលិកជាតិ ក្នុងរយៈពេលនៃពាក់កណ្តាលឆ្នាំ ២០១៥ ដែលនាំឱ្យមានផលប៉ះពាល់ដល់ការផ្តោតនិងសីលធម៌របស់បុគ្គលិក។

១១. បន្ទាប់ពីមានការប្តេជ្ញាចិត្តគាំទ្រពីមុនពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ មហាសន្និបាតបានអនុញ្ញាតឲ្យអគ្គលេខាធិការ ក្នុងនាមជាវិធានការពិសេស សន្យាជាផ្លូវការក្នុងការផ្តល់ថវិកាចំនួនមិនលើសពី ១២.១ លានដុល្លាអាមេរិក នៅក្នុងសេចក្តីសម្រេចចិត្តរបស់ខ្លួនលេខ ៧០/២៤៨ ដើម្បីបន្ថែមទៅលើធនធានហិរញ្ញវត្ថុស្ម័គ្រចិត្តរបស់ភាគីអន្តរជាតិ នៃ អ.វ.ត.ក. សម្រាប់រយៈពេលចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។ វិធានការទាន់ពេលវេលានេះ នឹងជួយសម្រួលយ៉ាងខ្លាំងដល់ប្រតិបត្តិការដ៏រលូនរបស់ អ.វ.ត.ក. នៅក្នុងឆ្នាំថ្មីនេះ ដោយបើកចំហរសម្រាប់ការអំពាវនាវជាបន្តរកការផ្តល់វិភាគទានស្ម័គ្រចិត្ត។ ជាងនេះទៀត ការសន្យាផ្តល់វិភាគទានដោយផ្ទាល់របស់រាជរដ្ឋាភិបាល ដូចឆ្នាំ២០១៥ ដែរ ដើម្បីចំណាយលើថ្លៃបុគ្គលិកជាតិក្នុងរយៈពេលប្រាំមួយខែដំបូង ក៏ដូចជាថ្លៃប្រតិបត្តិការដែលមានក្នុងឆ្នាំ២០១៦ គឺជាវិធានការបំពេញបន្ថែមយ៉ាងសំខាន់ ដែលជួយសម្រួលដំណើរការប្រតិបត្តិការជាបន្តរបស់ភាគីជាតិនៃ អ.វ.ត.ក.។ ជារួមវិធានការទាំងអស់នេះ ធានាបានថាដំណាក់កាលបន្តបន្ទាប់នៃបន្ទុកការងារដ៏ច្រើនខ្លាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ បន្តទទួលបានការចាប់អារម្មណ៍ជានិច្ចក្នុងឆ្នាំ២០១៦។ ការប៉ាន់ស្មានលើតារាងកំណត់ពេលវេលាខាងក្រោម ត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋានថា អង្គជំនុំជម្រះ និងការិយាល័យទាំងអស់មានបុគ្គលិកគ្រប់គ្រាន់ និងថាកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការ នឹងមិនត្រូវរំខានបន្ថែមទៀតដោយសារតែអសន្តិសុខផ្នែកហិរញ្ញវត្ថុ។ ប្រសិនបើអសន្តិសុខផ្នែកហិរញ្ញវត្ថុលេចឡើង យើងអាចចាំបាច់ត្រូវកែសម្រួលតារាងពេលវេលានេះឡើងវិញ។

១២. ការប៉ាន់ស្មាននានាលើគម្រោងបញ្ចប់ផែនការជំនុំជម្រះក្តីក្នុងសំណុំរឿង០០២/០២ បណ្តឹងសាទុក្ខលើសំណុំរឿង០០២/០១ និងការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤ សន្មតថាសកម្មភាពទាំង

អស់ កំពុងត្រូវបានធ្វើឡើងដំណាលៗគ្នា។ រហូតដល់ការបិទបញ្ចប់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០១ ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ក៏ដូចជាសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី នឹងចូលរួមទាំងបណ្តឹងសាទុក្ខសំណុំរឿង០០២/០១ និង ការជំនុំជម្រះក្តីសំណុំរឿង០០២/០២ នៅពេលទន្ទឹមគ្នា។ សហព្រះរាជអាជ្ញនឹងចូលរួមក្នុងពេលជាមួយគ្នានៅក្នុងរឿងក្តីទាំងពីរនេះ ក្នុងចំណោមរឿងក្តីទាំងអស់ ព្រមទាំងការស៊ើបអង្កេត និង ការរៀបចំសារណាបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០៣ និង ០០៤។

១៣. នៅខែមករា ឆ្នាំ២០១៥ កិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក. បានអនុម័តវិសោធនកម្មទៅលើវិធានផ្ទៃក្នុង ដែលអនុញ្ញាតឱ្យមានការកាត់បន្ថយទៅលើវិសាលភាពកិច្ចស៊ើបសួរ ដ៏រាបណាវិសាលភាពស៊ើបអង្កេតដែលបានកាត់បន្ថយ ជាតំណាងឱ្យបទចោទ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនសង្ស័យតាមការចោទប្រកាន់។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងអាចកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះក្តីដោយដកចេញអង្គហេតុជាក់លាក់មួយចំនួនដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដ៏រាបណាអង្គហេតុដែលនៅសល់ដែលត្រូវជំនុំជម្រះគឺជាដំណាងនៃវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ វិសោធនកម្មទាំងនេះប្រសិនបើអនុវត្តបាន គឺអាចពន្លឿនការបញ្ចប់កិច្ចនីតិវិធីស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបន្តវាយតម្លៃទៅលើថាតើវិធានថ្មីទាំងនេះអាចយកមកអនុវត្ត ដើម្បីពង្រួញវិសាលភាពនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤ ដែរ ឬយ៉ាងណា។

១៤. ក្នុងគោលបំណងបង្កើនសមត្ថភាពស៊ើបអង្កេត របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្រសួងយុត្តិធម៌បានផ្តល់នីតិសម្បទាដល់មន្ត្រីច្បាប់អន្តរជាតិចំនួនប្រាំបួននាក់ ដើម្បីចុះធ្វើកំណត់ហេតុស្តាប់ចម្លើយ ហើយកិច្ចការនេះជាធម្មតាគឺត្រូវបំពេញដោយអ្នកស៊ើបអង្កេតប៉ុណ្ណោះ។ ការបង្កើនសមត្ថភាពក្នុងការចុះធ្វើកំណត់ហេតុស្តាប់ចម្លើយនេះ នឹងជំរុញឱ្យដំណាក់កាលស៊ើបសួរបានលឿន។ ជាងនេះទៀតសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចាប់អនុវត្តគំនិតផ្តួចផ្តើមនានា ដើម្បីបង្កើនធនធានមនុស្សរបស់ខ្លួនជាមួយនឹងបុគ្គលិកជំនាញក្រោមកម្មវិធីដែលមិនត្រូវសងវិញ និងកម្មសិក្សាការីបន្ថែមទៀត ដើម្បីបង្កើនផលិតភាពនៃកិច្ចស៊ើបសួរ។ សមត្ថភាពបំពេញកិច្ចស៊ើបសួរត្រូវបានបង្កើនថែមទៀត នៅពេលដែលអ្នកស៊ើបអង្កេតអន្តរជាតិថ្មីបីរូបបានចូលបម្រើការងារនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងត្រីមាសទី១ ឆ្នាំ២០១៥ ហើយអ្នកស៊ើបអង្កេតអន្តរជាតិថ្មីបីរូបនេះបំពេញកិច្ចការក្នុងរយៈពេលបណ្តោះអាសន្នតែប៉ុណ្ណោះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបន្តទាក់ទងរដ្ឋជាសមាជិក និងអង្គការវិជ្ជាជីវៈនានាក្នុងគោលបំណងជ្រើសរើសអ្នកស៊ើបអង្កេតបន្ថែមមកបំពេញការងារជាបុគ្គលិកមិនយកប្រាក់កម្រៃ។

១៥. ការិយាល័យរដ្ឋបាល ក្នុងអំឡុងពេលត្រីមាសទីបី និងទីបួន ឆ្នាំ២០១៥ បានជ្រើសរើសបុគ្គលិកបកប្រែភាសាក្រៅក្របខណ្ឌមួយចំនួន ដើម្បីគាំទ្រដល់ការិយាល័យតុលាការ និងអង្គជំនុំជម្រះ ដើម្បីធានាបាននូវសេវាបកប្រែភាសាទាន់ពេលវេលា។

## III. ផែនការបញ្ចប់ការស៊ើបអង្កេត

១៦. តារាងកំណត់ពេលវេលានៃការបញ្ចប់ការស៊ើបអង្កេត ត្រូវបានកំណត់ដោយកត្តានានាដូចជា៖ ប្រភេទ និងភាពស្មុគស្មាញនៃរឿងក្តី ចំនួនសាក្សីដែលត្រូវស្តាប់សក្ខីកម្ម ចំនួនបេសកកម្មចុះដល់ទីកន្លែងដែលតម្រូវឱ្យមាន លទ្ធភាពមានបុគ្គលិកមានគុណវុឌ្ឍិ និងសម័ត្ថភាពក្នុងការរក្សាទុកបុគ្គលិកដែលមានបទពិសោធន៍ឧបសគ្គជាក់ស្តែងនិងឧបសគ្គធនធានសម្ភារៈក្នុងការបំពេញកិច្ចស៊ើបសួរ។ ក្នុងបរិបទនេះ វាមានសារៈសំខាន់ក្នុងការបង្ហាញថា ការស៊ើបអង្កេតមិនអាចអនុវត្តទៅបានយ៉ាងស៊ីចង្វាក់គ្នា និងទៀងទាត់គ្រប់ពេលបានឡើយនៅទូទាំងឆ្នាំ ក៏ដូចជាក្នុងបរិយាកាសផ្សេងទៀតផងដែរ។ មានថ្ងៃឈប់សម្រាកបុណ្យជាតិជាច្រើន និងក្នុងអំឡុងពេលបង្កបង្កើនផលស្រូវ និងនៅរដូវប្រមូលផលស្រូវ ជាញឹកញាប់ប្រជាជនមិនមានពេលទំនេរដើម្បីផ្តល់បទសម្ភាសន៍នោះទេ។ ជាងនេះទៀត ទីតាំងដាច់ស្រយាលមួយចំនួន ជាក់ស្តែងបេសកកម្មមិនអាចធ្វើដំណើរ

ចូលទៅដល់បានទេ ក្នុងផ្នែកខ្លះនៅរដូវភ្លៀង។ ចំនួនញត្តិដែលដាក់ដោយភាគីនានា ថិរវេលាដែលតម្រូវដោយអង្គបុរេជំនុំជម្រះដើម្បីចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្អូរបស់ភាគីនានា ក៏ជាការពិចារណាដែលពាក់ព័ន្ធផងដែរ។ ដោយមានកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជាមុននូវតារាងកំណត់ពេលវេលាអនុវត្តគ្រោងការ គឺផ្អែកលើបទពិសោធន៍កន្លងទៅនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងត្រូវគិតទុកជាមុនថាជាការប៉ាន់ស្មានជារួម។ វាក៏មានសារៈសំខាន់ផងដែរក្នុងការស្វែងយល់ថា កត្តាដែលបានរៀបរាប់មួយចំនួនខាងលើ គឺសុទ្ធតែហួសពីការគ្រប់គ្រងរបស់សហចៅក្រមស៊ើបអង្កេត ក៏ដូចជាគម្រោងដែលបានគ្រោងទុកដែរ។

១៧. ដោយសារតែការិយាល័យសហចៅក្រមស៊ើបអង្កេត កំពុងធ្វើការបានមួយកម្រិតដោយមានជំនួយពីបុគ្គលិកមិនយកប្រាក់កម្រៃដែលបានផ្តល់ជូនអង្គជំនុំជម្រះវិសាមញ្ញដោយរដ្ឋនានា បុគ្គលិកប្រឹក្សាការ កម្មសិក្សាការី និងការគាំទ្រស្ម័គ្រចិត្តដ៏មានបទពិសោធន៍ខ្ពស់ ស្ថានភាពបុគ្គលិកអាចទទួលយកការងារបន្ថែមដែលមិនរំពឹងទុកដ៏តិចតួច ដោយសារតែការផ្លាស់ប្តូរភ្លាមៗក្នុងកិច្ចខិតខំប្រឹងប្រែងស៊ើបអង្កេត។ ឧទាហរណ៍ សហចៅក្រមស៊ើបអង្កេតនឹងបាត់បង់អ្នកស៊ើបអង្កេតមិនយកប្រាក់កម្រៃចំនួនបីរូប ក្នុងចំណោមអ្នកស៊ើបអង្កេតសរុបចំនួនប្រាំបីរូប ក្នុងរយៈពេលនៃត្រីមាសទីមួយ ឆ្នាំ២០១៦ ហើយអ្នកស៊ើបអង្កេតជំនួសមិនទាន់រកបាននៅឡើយទេ។ រយៈពេលដែលអ្នកជំនួសណាម្នាក់ត្រូវការដើម្បីសិក្សាស្វែងយល់ពីការស៊ើបអង្កេត នឹងចៀសមិនផុតពីការបាត់បង់សមត្ថភាពស៊ើបអង្កេតបន្ថែមទៀត។ មន្ត្រីច្បាប់ និងបុគ្គលិកប្រឹក្សាការស្ទើរតែទាំងអស់ ទទួលបាននីតិសម្បទាបន្ថែមទៀតជាអ្នកស៊ើបអង្កេតជាមួយអាជ្ញាធរកម្ពុជា ហើយត្រូវបំពេញតួនាទីពីរ ដើម្បីធ្វើឱ្យអត្រាស្តាប់ចម្លើយសាក្សីក្នុងចំនួនមួយដែលអាចទទួលយកបាន។ យ៉ាងណាមិញ ការអនុវត្តនេះមានផលប៉ះពាល់ជាប្រយោលលើល្បឿន ក្នុងការវិភាគញត្តិ និងការធ្វើសេចក្តីសម្រេច។

១៨. វិធានផ្ទៃក្នុងដាក់បញ្ញត្តិអំពីដំណាក់កាលនីតិវិធីផ្សេងៗ ដែលសហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តតាម ដើម្បីបំពេញឱ្យបានពេញលេញនូវដំណើរការស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតត្រូវស៊ើបអង្កេតអង្គហេតុនានាដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដែលដាក់ដោយសហព្រះរាជអាជ្ញា។ នៅពេលបំពេញកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចនឹងបំពេញកិច្ចស៊ើបសួរ ដែលនាំឱ្យបញ្ជាក់នូវការពិត។ នៅគ្រប់ករណីទាំងអស់ ពួកគេត្រូវបំពេញកិច្ចស៊ើបសួរដោយអនាគតិ ភាគីនានាអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរជាក់លាក់មួយចំនួន ហើយការណ៍នេះអាចនាំឱ្យមានកិច្ចខិតខំប្រឹងប្រែងស៊ើបអង្កេតសំខាន់ៗ អាស្រ័យលើកាលៈទេសៈជាក់ស្តែង។ ការបដិសេធមិនពិចារណាលើសំណើសុំ អាចនឹងត្រូវបានប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ បទពិសោធន៍បច្ចុប្បន្នបង្ហាញថា អង្គបុរេជំនុំជម្រះអាចត្រូវការចន្លោះពីបី ទៅប្រាំមួយខែ ដើម្បីធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍។ អាស្រ័យលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ និងលទ្ធផលរបស់វា សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍អាចមានផលប៉ះពាល់សំខាន់លើការស៊ើបអង្កេតដែលកំពុងធ្វើ និងបន្ថែមយ៉ាងច្រើនទៅលើពេលវេលាដែលត្រូវការបញ្ចប់ពួកវា។ ការណ៍នេះក៏ដូចគ្នាទៅនឹងសំណើសុំមោឃភាព ដែលដាក់ទៅកាន់អង្គបុរេជំនុំជម្រះផងដែរ ទាក់ទងនឹងការចោទប្រកាន់អំពីការបំពេញកិច្ចស៊ើបសួរខុសច្បាប់ ដោយសារតែសហចៅក្រមស៊ើបអង្កេតមិនមានអំណាចធ្វើមោឃភាពកិច្ចស៊ើបសួររបស់ខ្លួនផ្ទាល់។

១៩. នៅពេលសហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា ការស៊ើបអង្កេតត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងដល់ភាគីទាំងអស់ ដែលមានរយៈពេល១៥ថ្ងៃដើម្បីស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម លើកលែងតែភាគីបោះបង់រយៈពេលនោះចោល។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធចោលសំណើបែបនេះ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាសម្រេចមួយ ដែលមានសំអាងហេតុ។ នៅក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីការជូនដំណឹងអំពីដីកាសម្រេចនេះ ភាគីទាំងអស់អាចដាក់បណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ ដូច្នេះ អាចមានការពន្យារពេលដែលមិនអាចប្រមើលដឹងជាមុនបន្ថែមទៀត។ នៅពេលដែលរយៈពេលនេះបានផុតកំណត់ ត្រូវបានបោះបង់ចោល ឬបណ្តឹងឧទ្ធរណ៍ដែលបានលើកឡើងខាងលើត្រូវបានជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនសំណុំរឿងភ្លាមៗទៅឱ្យសហព្រះរាជអាជ្ញា ដើម្បី

ចេញដីកាសន្និដ្ឋានស្ថាពរ។ សហព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ និង បង្វិលសំណុំរឿងឲ្យសហចៅក្រមស៊ើបអង្កេត នៅក្នុងរយៈពេល៤៥ ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវបានឃុំខ្លួន និងរយៈពេល ៣ ខែ នៅក្នុងករណីផ្សេងៗទៀត។ លើកលែងតែក្រោយពេលដំណាក់កាលដែលលើកឡើងខាងលើនេះត្រូវបានបញ្ចប់ ទើបសហចៅក្រមស៊ើបអង្កេតអាចចេញដីកាដំណោះស្រាយ ថាតើត្រូវចោទប្រកាន់ជនត្រូវចោទ ដែលត្រូវបញ្ជូនរូបគាត់ទៅជំនុំជម្រះ ឬត្រូវទម្លាក់ចោលការចោទប្រកាន់។

២០. សហព្រះរាជអាជ្ញាអាចនឹងដាក់បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយទៅអង្គបុរេជំនុំជម្រះ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់បណ្តឹងឧទ្ធរណ៍ តែក្នុងករណីដីកាដំណោះស្រាយបដិសេធចោលការចោទប្រកាន់ និងក្នុងករណីដែលសហព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធចោលការចោទប្រកាន់នេះ។ បន្ថែមពីលើនេះ អង្គបុរេជំនុំជម្រះបានផ្តល់សិទ្ធិឲ្យជនត្រូវចោទជំទាស់នឹងធាតុផ្សំយុត្តាធិការនៅក្នុងដីកាដំណោះស្រាយតាមរយៈបណ្តឹងឧទ្ធរណ៍។ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ត្រូវតែដាក់នៅក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីដីកាសម្រេចនេះ។ អង្គបុរេជំនុំជម្រះអាចនឹងកែប្រែ ឬតម្កល់ដីកាដំណោះស្រាយនេះ។

២១. កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ បានចាប់ផ្តើមដំណើរការក្រោយពីការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅខែកញ្ញា ឆ្នាំ២០០៩ ចាប់តាំងពីពេលនោះមកមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរជាច្រើនត្រូវបានធ្វើឡើង។ ដោយអនុលោមតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. សហចៅក្រមស៊ើបអង្កេតបានធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នាជាច្រើនរវាងសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរក្នុងសំណុំរឿងទាំងនេះ ហេតុដូចនេះ សហចៅក្រមស៊ើបអង្កេតទាំងពីររូបកំពុងតែជ្រើសរើសវិធីសាស្ត្ររៀងៗខ្លួននៅក្នុងសំណុំរឿងទាំងនេះ។ គួរកត់សម្គាល់ថា ទោះបីជាមានទស្សនៈផ្សេងគ្នាលើបញ្ហាអង្គហេតុ និងអង្គច្បាប់មួយចំនួនយ៉ាងណាក្តី ក៏កិច្ចសហប្រតិបត្តិការរវាងសហចៅក្រមស៊ើបអង្កេតទាំងពីរ មានភាពល្អប្រសើរប្រកបដោយវិជ្ជាជីវៈខ្ពស់។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិកំពុងតែស៊ើបអង្កេតយ៉ាងសកម្ម លើការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ក្នុងសំណុំរឿង ០០៣ និង ០០៤។

២២. ចាប់តាំងពីការចាប់ផ្តើមការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ និង ០០៤ មានការបំពេញបេសកកម្មដល់ទីកន្លែងកើតហេតុសរុបចំនួន ២០១ លើក ហើយសាក្សីចំនួន ១.១០៩ នាក់ ត្រូវបានស្តាប់ចម្លើយ។ ក្នុងឆ្នាំ២០១៥ តែឯង មកទល់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ មានការបំពេញបេសកកម្មដល់ទីកន្លែងកើតហេតុចំនួន ៦៣ លើក (៣១.៣% នៃចំនួនសរុប) និងបានបញ្ចប់ការស្តាប់ចម្លើយសាក្សីចំនួន ៤២១ នាក់ (៣៨% នៃចំនួនសរុប)។ ជាងនេះទៀត ការស៊ើបអង្កេតសំខាន់មួយទាក់ទងនឹងឯកសារអ្នកទោស ស-២១ កំពុងត្រូវបានធ្វើឡើង និងមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ថ្មីៗនេះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏បានផ្តួចផ្តើមឱ្យធ្វើទៅជាឌីជីថលនូវខ្សែអាត់សំឡេងទាំអស់ដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ក្នុងគោលបំណងដើម្បីដាក់ឯកសារទាំងនោះទៅក្នុងសំណុំរឿង ០០៣ និង ០០៤ ដើម្បីកុំឱ្យភាគីដាក់ញត្តិស្នើសុំការធ្វើឌីជីថល*ចំពោះកិច្ច*នាពេលអនាគត ហេតុដូច្នេះវាកាត់បន្ថយពេលវេលាតុលាការ និងពេលវេលារបស់ក្រុមក្នុងការចំណាយពេលលើញត្តិបែបនោះ ហើយវាក៏ជួយកាត់បន្ថយបន្ថែមទៀតទៅលើពេលវេលាដែលត្រូវការសម្រាប់កិច្ចស៊ើបសួរ។ គម្រោងនេះកំពុងត្រូវបានរៀបចំឡើងនាពេលបច្ចុប្បន្ន ហើយត្រូវបានរំពឹងថានឹងបញ្ចប់ក្នុងត្រីមាសទី១ នៃឆ្នាំ២០១៦។ ការិយាល័យសហចៅក្រមស៊ើបអង្កេតនឹងមិនអាចសម្រេចការងារបានដោយមិនមានការប្រើប្រាស់ពេលវេលាដ៏ច្រើនរបស់កម្មសិក្សាការីនោះឡើយ ដែលការណ៍នេះឆ្លុះបញ្ចាំងនូវមតិយោបល់អំពីកម្រិតនៃការផ្គត់ផ្គង់បុគ្គលិកខាងលើ។

២៣. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានធ្វើការពិនិត្យឡើងវិញ នូវរាល់ការស៊ើបអង្កេតដែលនៅសេសសល់ទាំងអស់ក្នុងសំណុំរឿង ០០៣ និង ០០៤ ក្នុងត្រីមាសទី៤ នៃឆ្នាំ២០១៥ ហើយមតិយោបល់ខាងក្រោម

នេះត្រូវបានផ្អែកលើការពិនិត្យឡើងវិញនោះ។ លក្ខណៈរីកចម្រើននៃការស៊ើបអង្កេតក្នុងរឿងក្តីទាំងពីរ គឺ ០០៣ និង ០០៤ ដែលបានបង្កើតឡើងក្នុងអំឡុងពេលពិនិត្យឡើងវិញនេះ បង្ហាញថា ការប៉ាន់ស្មានតារាងពេលវេលាពីមុន ក្នុងកាលៈទេសៈនានា មានលក្ខណៈសុទិដ្ឋិនិយមជ្រុលហួស ដោយសារតែសកម្មភាពស៊ើបអង្កេតចាំបាច់មួយចំនួន ដែលមិនអាចបញ្ចប់ទៅបាន ដូចការរំពឹងទុកនាពេលនោះ។ ជាពិសេស រឿងក្តី យឹម ទិត្យ នឹងមានការប៉ះពាល់សំខាន់លើការរីកចម្រើននៃការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ ដោយសារថា ផ្នែកនៃការស៊ើបអង្កេតបានដំណើរទៅមុខដោយមិនមានធាតុចូលសំខាន់ពីភាគីការពារក្តី រហូតមកទល់សេចក្តីសម្រេចនាពេលថ្មីៗនេះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានផ្តល់សិទ្ធិឱ្យចូលពិនិត្យសំណុំរឿង នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៥។ យឹម ទិត្យ ត្រូវបានចោទប្រកាន់នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ នៅពេលបង្ហាញខ្លួនលើកដំបូងរបស់គាត់ ដែលគាត់បានបង្ហាញខ្លួនដោយផ្ទាល់ តាមដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ជនត្រូវចោទ និងមេធាវីរបស់គាត់ នឹងត្រូវការពេលវេលាជាច្រើនដើម្បីស្វែងយល់សម្ភារៈដែលបានប្រមូលតាំងពីដើមមកក្នុងអំឡុងពេលស៊ើបអង្កេត ដែលបានបន្តតាំងពីឆ្នាំ២០០៩ មុនពេលពួកគេអាចចូលរួមក្នុងសំណុំរឿងនេះប្រកបដោយអត្ថន័យ។ សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរជាច្រើន និងញត្តិផ្សេងៗទៀត ពេលនេះអាចរំពឹងថាត្រូវបានដាក់ដោយក្រុមមេធាវីការពារក្តី នៅពេលដែលពួកគេបានស្វែងយល់សំណុំរឿងបានគ្រប់គ្រាន់។ ដូច្នេះ ការព្យាករណ៍ណាមួយទាក់ទងនឹងពេលវេលានៅសល់ សម្រាប់ផ្នែកជាក់លាក់នៃសំណុំរឿង ០០៤ នោះមានលក្ខណៈប៉ាន់ស្មាននាពេលនេះ ដោយសារតែយថាភាពទាំងអស់នេះ។ អង្គហេតុនេះក៏ពាក់ព័ន្ធទៅនឹងបញ្ហាចោទនៃការបំបែកសំណុំរឿងតូចៗ ក្នុងសំណុំរឿង ០០៤ ផងដែរ សម្រាប់ជនត្រូវចោទទាំងអស់នោះ ដែលការស៊ើបអង្កេតរបស់ពួកគេបានកំពុងដំណើរការទៅមុខ ដោយមានការចូលរួមរបស់ពួកគេអស់រយៈពេលប្រាំបួនខែមកហើយ។

២៤. ជនត្រូវចោទក្នុងសំណុំរឿង ០០៣ មាស មុត បានស្ម័គ្រចិត្តអនុវត្តតាមដីកាកោះដែលបានកែប្រែថ្មីមកបង្ហាញខ្លួនលើកដំបូង នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ហើយត្រូវបានចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះបទឧក្រិដ្ឋដែលបានចោទប្រកាន់សរុបទាំងអស់ ដែលបានគាំទ្រដោយស្ថានភាពនៃការស៊ើបអង្កេតបច្ចុប្បន្ន ផ្ទុយទៅនឹងសេចក្តីសម្រេចនៃការចោទប្រកាន់ដោយកំបាំងមុខចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ដែលមានលក្ខណៈដោយផ្នែក ដូច្នេះសេចក្តីសម្រេចចោទប្រកាន់ពីមុនក្លាយទៅជាមោឃៈ ហើយ ដីកាបង្គាប់ឱ្យនាំខ្លួនក៏ត្រូវមោឃៈផងដែរ។

២៥. ទាក់ទងនឹងជនត្រូវចោទក្នុងសំណុំរឿង ០០៤ អ៊ឹម ចែម ការជូនដំណឹងមួយអំពីការបិទបញ្ចប់កិច្ចស៊ើបសួរ ត្រូវបានធ្វើឡើងនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ ដោយសហចៅក្រមស៊ើបអង្កេតទាំងពីរ ហើយភាគីអាចដាក់សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរក្នុងរយៈពេល ១៥ ថ្ងៃ នៃការជូនដំណឹងនេះ។

២៦. នាពេលនេះ សហចៅក្រមស៊ើបអង្កេតមានបំណងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនត្រូវចោទទាំងបីរូប ក្នុងសំណុំរឿង ០០៤ ដោយសារតែការស៊ើបអង្កេតរបស់ពួកគេនីមួយៗឈានជិតបញ្ចប់ហើយ ទោះជាយ៉ាងណា ភាគីនឹងត្រូវបានពិគ្រោះយោបល់លើបញ្ហានេះ នៅក្នុងរឿងក្តីនីមួយៗ។ ការព្យាករណ៍ពេលវេលាដ៏ល្អបំផុត ដែលអាចផ្តល់ជូននាពេលនេះគឺដូចខាងក្រោម៖

(i) ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ទាក់ទងនឹង មាស មុត នឹងត្រូវបិទបញ្ចប់ត្រឹមត្រីមាសទីបី ក្នុងឆ្នាំ២០១៦។

(ii) ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ អាស្រ័យលើថាតើសំណុំរឿងនឹងត្រូវបំបែកឬអត់ នឹងបិទបញ្ចប់ត្រឹមត្រីមាសទីបួន ឆ្នាំ២០១៥ សម្រាប់ជនត្រូវចោទ អ៊ឹម ចែម និងនៅថ្ងៃត្រីមាសទីពីរ ក្នុងឆ្នាំ២០១៦ សម្រាប់ អោ អាន ចំណែកជនត្រូវចោទថ្មីៗនេះ គឺ យឹម ទិត្យ នឹងមិនមុនចុងត្រីមាសទីបួន ក្នុងឆ្នាំ២០១៦ នោះបានទេ។

(iii) ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ នឹងចេញត្រឹមត្រីមាសទីបួន ឆ្នាំ២០១៦។

(iv) ដីកាដំណោះស្រាយមួយ(ច្រើន) ក្នុងសំណុំរឿង ០០៤ អាស្រ័យលើថាតើសំណុំរឿងនឹងត្រូវបំបែក ឬអត់ ហើយប្រសិនបើបំបែក តើបំបែកដោយរបៀបណា នឹងចេញត្រឹមត្រីមាសទីពីរ ក្នុងឆ្នាំ២០១៦ សម្រាប់ អ៊ឹម ចែម ត្រីមាសទីបួន ក្នុងឆ្នាំ២០១៦ សម្រាប់ អោ អាន និង ត្រឹមត្រីមាសទីពីរ ក្នុងឆ្នាំ ២០១៧ សម្រាប់ យឹម ទិត្យ។

(v) បណ្ដឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយ នឹងត្រូវសម្រេចដោយអង្គបុរេជំនុំជម្រះ ត្រឹមត្រីមាសទីពីរ ក្នុងឆ្នាំ២០១៧ សម្រាប់សំណុំរឿង ០០៣ និងត្រីម៉ាសទីបួនក្នុងឆ្នាំ២០១៧ សម្រាប់ សំណុំរឿង ០០៤។

២៧. ការប៉ាន់ប្រមាណពេលវេលាទាំងនេះនៅតែអាស្រ័យលើកត្តាជាច្រើន ដែលបានកំណត់កាលពីមុន ជាអាទិ៍ ដូចជា ការរក្សាទុកបុគ្គលិកសំខាន់ៗ ថវិការគ្រប់គ្រាន់សម្រាប់ការជ្រើសរើសបុគ្គលិកថ្មីទៅតាម តំណែងដែលនៅទំនេរ ការបកប្រែភាសាទាន់ពេលវេលា សមត្ថភាពបកប្រែផ្ទាល់មាត់និងការធ្វើប្រតិចារឹកគ្រប់ គ្រាន់សម្រាប់បេសកកម្មនៅតាមមូលដ្ឋាន និងការសម្ភាសន៍សាក្សី ដំណោះស្រាយទាន់ពេលវេលាទៅលើបណ្ដឹង ឧទ្ធរណ៍នៅអង្គបុរេជំនុំជម្រះ និងការគាំទ្រពេញលេញពីសំណាក់នគរបាលយុត្តិធម៌។

## IV. ផែនការបញ្ចប់សវនាការ

២៨. តារាងកំណត់ពេលវេលានៃការបញ្ចប់សវនាការត្រូវកំណត់ដោយកត្តានានាដូចជា លក្ខណៈ និង ភាពស្មុគ ស្មាញនៃសំណុំរឿង បញ្ហាសុខភាពរបស់ជនជាប់ចោទដែលមានវ័យចាស់ជរា ចំនួនសាក្សី ដើមបណ្ដឹង រដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវកោះហៅ លទ្ធភាពចូលរួមបានរបស់ពួកគេ និងរយៈពេលនៃការធ្វើសក្ខីកម្ម របស់សាក្សីទាំងនោះ ការបង្អាក់ជាក់ស្ដែងនានាក្នុងការបំពេញកិច្ចដំណើរការនីតិវិធី ចំនួនញត្តិដាក់ដោយភាគី និងការពិនិត្យពិច័យផ្នែករដ្ឋបាលផ្សេងៗទៀត រួមមានការបកប្រែភាសាបានត្រឹមត្រូវ នឹងការបកប្រែឯកសារ បានទាន់ពេលវេលា។ ដោយមានកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជាមុននូវតារាងកំណត់ពេលវេលាអនុវត្ត គ្រោងការ គឺផ្អែកលើបទពិសោធន៍កន្លងទៅ ទាំងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងស្ថាប័នតុលាការប្រហាក់ ប្រហែលគ្នា។

២៩. ការប្រជុំរៀបចំសវនាការចំនួនមួយ ឬច្រើន តែងតែបានរៀបចំឡើងមុនពេលការចាប់ផ្ដើមសវនា ការជាក់ស្ដែង។ សវនាការចាប់ផ្ដើមដោយសវនាការបឋម។ នៅក្នុងសវនាការបឋមនេះ អង្គជំនុំជម្រះសាលា ដំបូង ពិចារណាទៅលើបញ្ជីសាក្សីសក្ខីនុពល និងអ្នកជំនាញ ដែលដាក់ជូនដោយភាគី ព្រមទាំងអញ្ញត្រកម្ម លើកឡើងដោយភាគី ហើយភាគីដើមបណ្ដឹងរដ្ឋប្បវេណីអាចផ្ដួចផ្ដើមនូវចំណុចជាក់លាក់អំពីសំណងដែលខ្លួន ស្នើសុំ។ សវនាការលើអង្គសេចក្ដីចាប់ផ្ដើមដោយមានការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ដោយសង្ខេបពី សំណាក់សហព្រះរាជអាជ្ញា ហើយជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបាន មុនពេលអង្គជំនុំជម្រះ សាលាដំបូង ចាប់ផ្ដើមតាំងសំណួរដល់ជនជាប់ចោទ ភាគីដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី និងស្ដាប់នូវការ បង្ហាញភ័ស្ដុតាង។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីផ្ដន្ទាទោសជន ជាប់ចោទអង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿ ដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ក្រោយពេលពិនិត្យភ័ស្ដុតាងទាំងអស់រួចហើយ អង្គជំនុំជម្រះស្ដាប់ការបិទកិច្ចពិភាក្សាដេញដោលពីសំណាក់ ភាគី មុនពេលពិភាក្សាគ្នាជាសម្ងាត់ដើម្បីសម្រេចសេចក្ដី។ ប្រសិនបើជនជាប់ចោទត្រូវផ្ដន្ទាទោស អង្គជំនុំជម្រះ សម្រេចទៅលើទោសសមស្របដែលបានកំណត់នៅក្នុងសាលក្រមរបស់ខ្លួន។ ដោយឈរលើមូលដ្ឋាននៃជំហាន នីតិវិធីទាំងនេះទើបយើងកំណត់បាននូវគ្រោងការសំខាន់ៗផ្សេងៗគ្នាសម្រាប់សវនាការនីមួយៗបាន។

### ក. សំណុំរឿង០០២/០២

៣០. នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញនូវសេចក្តីសម្រេចបំបែកសំណុំរឿងថ្មីមួយទៀត ដោយកំណត់វិសាលភាពក្នុងសំណុំរឿង០០២/០២ ដែលជាការជំនុំជម្រះក្តីវគ្គទីពីរប្រឆាំងនឹង ខៀវ សំផន និង នួន ជា។ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ទីតាំងបទល្មើសដែលបានចោទប្រកាន់ និងការចោទប្រកាន់តាមអង្គហេតុបង្កើតបានជាមូលដ្ឋាននៃសំណុំរឿង០០២/០២៖ អំពើប្រល័យពូជសាសន៍លើជនជាតិចាម និងជនជាតិវៀតណាម (មិនរាប់បញ្ចូលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលប្រព្រឹត្តដោយកងទ័ពបដិវត្តកម្ពុជា នៅលើទឹកដីវៀតណាម) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ (ទូទាំងប្រទេស) ការបោសសម្អាតផ្ទៃក្នុង មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល ការដ្ឋានទំនប់១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្ម សហករណ៍នៅត្រាំកក់ ការប្រព្រឹត្តិមកលើពុទ្ធសាសនិក (កម្រិតត្រឹមតែសហករណ៍ត្រាំកក់) និងការប្រព្រឹត្តិមកលើអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ (ការអនុវត្តកម្រិតត្រឹមតែសហករណ៍ត្រាំកក់ ការដ្ឋានទំនប់១មករា មន្ទីសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់)[8]។ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ អង្គជំនុំជម្រះតុលាការកំពូល តម្កល់សេចក្តីសម្រេចបំបែកសំណុំរឿងថ្មីនេះ។

៣១. អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការបឋមបន្ថែមទៀតក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤។ នៅក្នុងសវនាការនោះ អង្គជំនុំជម្រះសាលាដំបូង ស្តាប់សារណារបស់ភាគីទៅលើលំដាប់លំដោយនៃនីតិវិធីជំនុំជម្រះបន្ថែមទៅលើសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួនលើវិសាលភាពនៃសំណុំរឿង០០២/០២ ហើយនិងសំណើរបស់ភាគីទាក់ទងនឹងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវស្តាប់សក្ខីកម្ម។ អង្គជំនុំជម្រះក៏បានផ្តល់ឱកាសដល់ដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញនូវបញ្ហាកាន់តែជាក់លាក់ថែមទៀតទៅលើសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។

៣២. នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ។ បន្ទាប់មក ខៀវ សំផន និង នួន ជា បានបង្ហាញភាពមិនពេញចិត្តក្នុងការចូលរួមក្នុងកិច្ចនីតិវិធី ក្នុងសំណុំរឿង០០២/០២ លុះត្រាតែមានដំណោះស្រាយទៅលើបញ្ហាជាក់លាក់នានា ហើយបានបង្គាប់ឱ្យមេធាវីការពារក្តីរបស់ខ្លួនអនុវត្តទៅតាមការណែនាំរបស់ខ្លួន។ នួន ជា បានចូលរួមសាជាថ្មីនៅក្នុងសំណុំរឿង០០២/០២ នៅថ្ងៃទី១៧ ខែវិច្ឆិកា ចំណែកឯមេធាវីការពារក្តី ខៀវ សំផន បន្តពហិការមិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ដោយបង្ខំឱ្យអង្គជំនុំជម្រះសាលាដំបូងផ្អាកកិច្ចនីតិវិធីសវនាការលើភ័ស្តុតាងរហូតដល់ ខែមករា ឆ្នាំ២០១៥។

៣៣. កិច្ចដំណើរការនីតិវិធីលើភ័ស្តុតាងបានចាប់ផ្តើមនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ដោយអង្គជំនុំជម្រះត្រូវធ្វើសវនាការចំនួនបីថ្ងៃក្នុងមួយសប្តាហ៍។ លទ្ធផលនៃការវាយតម្លៃផ្នែកវេជ្ជសាស្ត្ររបស់ជនជាប់ចោទនៅខែមករា ឆ្នាំ២០១៥ បង្ហាញថា ការកំណត់៤ថ្ងៃ ក្នុង១សប្តាហ៍ជាការសមស្រប ដោយសវនាការពេលព្រឹកធ្វើឱ្យបានខ្លីបន្តិច។ ដូច្នេះអង្គជំនុំជម្រះបានត្រឡប់ទៅអនុវត្តតាមពេលកំណត់៤ថ្ងៃក្នុង១សប្តាហ៍វិញ នៅខែកុម្ភៈ ដែលជាការពន្លឿនដល់ការជំនុំជម្រះក្តី។ ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មសាក្សីចំនួន ៥៦ នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣០ នាក់ និង អ្នកជំនាញចំនួនម្នាក់ ស្តីពីសហករណ៍ត្រាំកក់ (រួមបញ្ចូល មន្ទីរសន្តិសុខក្រាំងតាចាន់ និងការប្រព្រឹត្តិលើពុទ្ធសាសនិក) ការដ្ឋានទំនប់ ១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្ម ក៏ដូចជាការប្រព្រឹត្តិលើជនជាតិចាម និងជនជាតិវៀតណាម។

---

[8] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមទៀត នៃសំណុំរឿង ០០២ និង វិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ E301/9/1 ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤។

៣៤. ចំនួនថ្ងៃសម្រាប់បើកនិងបញ្ចប់សវនាការពេញលេញ អាចស្មានទុកបានក្នុងសំណុំរឿង ០០២/០២ តែនៅពេលណាដែលចំនួនទូទៅនៃសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលត្រូវកោះហៅ មានការកំណត់ច្បាស់លាស់ហើយដោយអង្គជំនុំជម្រះសាលាដំបូង។ សក្ខីកម្មសរុបចំនួន ២៦៥ ត្រូវបានស្នើឡើងដោយភាគី។ សក្ខីកម្មចំនួន ៤៥ បន្ថែមទៀតរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញថ្មី ត្រូវបានស្នើឡើងតាំងពីចាប់ផ្តើមសវនាការ។ ដូច្នេះ ការស្មានទុកពេលបច្ចុប្បន្នទាក់ទិននឹងតារាងពេលវេលានៃសំណុំរឿង០០២/០២ គឺផ្អែកទៅលើការសន្មតថា សវនាការទីពីរនឹងមានលក្ខណៈស្មុគស្មាញ និងត្រូវការពេលវេលាដូចគ្នានឹងសវនាការ០០២/០១ ដែរ ប៉ុន្តែអាចខុសប្លែកពីគ្នាច្រើន នៅពេលដែលកត្តានេះត្រូវបានកំណត់ពេញលេញ។

៣៥. តាំងពីការចាប់ផ្តើមសវនាការលើភ័ស្តុតាងក្នុងខែមករា ឆ្នាំ២០១៥ មិនមានសញ្ញាបន្ថែមទៀតនៃការពហិការជាថ្មីក្នុងការជំនុំជម្រះក្តីសំណុំរឿង ០០២/០២ ឡើយ។ យ៉ាងណាមិញ ការស្តាប់ចម្លើយរាប់រយត្រូវបានដាក់បង្ហាញពីការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ និង ០០៤ ទៅកាន់ភាគីក្នុងសំណុំរឿង ០០២ ដែលតម្រូវឱ្យអង្គជំនុំជម្រះផ្អាកសវនាការជាច្រើនសប្តាហ៍ ដើម្បីឱ្យភាគីពិនិត្យមើលសម្ភារៈថ្មីនេះ។ ការដាក់បង្ហាញនេះក៏នាំឱ្យមានសំណើពីភាគីនានាស្នើឱ្យស្តាប់សវនាការសាក្សីបន្ថែមផងដែរ។ ជាងនេះទៀត ភាគីចាំបាច់ត្រូវទទួលបានពេលវេលាដើម្បីរៀបចំ និងចូលរួមក្នុងសវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ផងដែរ។

៣៦. អង្គជំនុំជម្រះសាលាដំបូងពេលនេះបានវាយតម្លៃផលប៉ះពាល់រួមនៃការពហិការរបស់ភាគីការពារក្តីកាលពីត្រីមាសចុងក្រោយក្នុងឆ្នាំ២០១៤ ការពន្យារពេលតុលាការដើម្បីពិនិត្យឯកសារដែលបានដាក់បង្ហាញពីសំណុំរឿង ០០៣ និង ០០៤ និងពេលវេលាផ្តល់ឱ្យភាគីដើម្បីត្រៀមសម្រាប់សវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ដែលបានប្រមើលទុក។ ទោះបីជាកត្តាទាំងអស់នេះជារួមនាំឱ្យមានការបាត់បង់ពេលវេលាជាងបួនខែ នៃពេលសវនាការយ៉ាងណាក្តី ក៏វឌ្ឍនភាពដែលអង្គជំនុំជម្រះមាននៅក្នុងការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ជាពិសេសក្នុងរយៈពេលប្រាំមួយខែដំបូងក្នុងឆ្នាំ២០១៥ ធ្វើឱ្យវាមានភាពចាំបាច់នៅពេលនេះក្នុងការរំកិលគ្រោងការសំខាន់ៗដែលរំពឹងទុកសម្រាប់ការបញ្ចប់កិច្ចនីតិវិធី ការធ្វើសេចក្តីសន្និដ្ឋានបិទការពិភាក្សាដេញដោល និងការចេញសាលក្រម រយៈពេលចំនួនបីខែរៀងៗខ្លួន។

៣៧. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា ចាំបាច់ត្រូវពិនិត្យមើលស្ថានភាពនេះឡើងវិញ នៅពាក់កណ្តាលឆ្នាំ២០១៦ ដើម្បីកំណត់ថាតើ ការប៉ាន់ស្មាននេះនៅតែត្រឹមត្រូវផ្អែកលើស្ថានភាពនៃការជំនុំជម្រះដូចដែលវាមានសុពលភាព។ ច្បាស់ណាស់ថា មុនពេលនោះ មានកត្តាជាច្រើនទំនងជាប៉ះពាល់បន្ថែមទៀតលើការគ្រោងទុកនេះ។ ឧទាហរណ៍ សវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ត្រូវបានរំពឹងថារៀបចំកាលវិភាគឡើងវិញ នៅដើមឆ្នាំ២០១៦ ដែលក្នុងពេលនោះ (រួមបញ្ចូលទាំងពេលវេលាតិចតួចសម្រាប់រៀបចំ) ភាគីមិនមានពេលចូលរួមសវនាការក្នុងពេលដំណាលគ្នាឡើយ។ ការដាក់បង្ហាញបន្ថែមទៀតពីសំណុំរឿង ០០៣ និង ០០៤ ក៏ត្រូវបានរំពឹងទុកផងដែរ ហើយការណ៍នេះអាចនាំឱ្យមានការពន្យារពេលបន្ថែមទៀត។ ក្នុងន័យនេះ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា កំណត់ហេតុស្តាប់ចម្លើយពាក់ព័ន្ធភាគច្រើនពីសំណុំរឿង០០៣ និង ០០៤ ដែលខ្លួនមានបច្ចុប្បន្ននេះ ត្រូវបានដាក់បង្ហាញរួចហើយ ក្នុងសំណុំរឿង ០០២/០២ ហើយដូច្នេះ ការពន្យារពេលបន្ថែមទៀតដែលបណ្តាលមកពីការដាក់បង្ហាញបន្ថែមនេះ ទំនងជាមិនច្រើនដូចកាលពីឆ្នាំ២០១៥ ទេ។

៣៨. អង្គជំនុំជម្រះសាលាដំបូងបានចាត់វិធានការដើម្បីដាក់កម្រិតបន្ថែមទៀតលើដំណើរការដាក់បង្ហាញនេះ ដោយប្រកាសថា សហព្រះរាជអាជ្ញាមានកាតព្វកិច្ចជាបន្តបន្ទាប់ក្នុងការដាក់បង្ហាញ ទៅកាន់ភាគីការពារក្តីនូវភ័ស្តុតាងដោះបន្ទុក ដែលមាននៅក្នុងសម្ភារៈណាមួយដែលបានដឹងដោយពិតប្រាកដថា អាចបង្ហាញពីភាពគ្មានទោស ឬជួយសម្រាលពិរុទ្ធភាពរបស់ជនជាប់ចោទ ឬប៉ះពាល់ដល់ភាពអាជឿជាក់បាននៃភ័ស្តុតាងដាក់បន្ទុក ហើយបានបង្គាប់ *ជាអាទិ៍* ឱ្យសហព្រះរាជអាជ្ញាស្វែងរកការអនុញ្ញាត ត្រឹមថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៦ យ៉ាងយូរ ឱ្យទទួលយកសម្ភារៈណាមួយក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលបានដាក់បង្ហាញមកទល់កាលបរិច្ឆេទនេះ ដាក់ក្នុងសំណុំរឿង ០០២/០២ ហើយដែលសហព្រះរាជអាជ្ញាមានបំណងពឹងផ្អែកលើ។ កត្តាផ្សេង

ទៀត ដែលពាក់ព័ន្ធជាសក្ដានុពលទៅនឹងរយៈពេលដែលបានស្មានទុកនៃការជំនុំជម្រះ ដែលអាចកើតមាននាពេលអនាគត រួមមានការប្រែប្រួលស្ថានភាពសុខភាពរបស់ជនជាប់ចោទ ដែលបង្កើតឱ្យមានតម្រូវការកាត់បន្ថយចំនួនថ្ងៃធ្វើសវនាការក្នុងសប្ដាហ៍ និង/ឬ រយៈពេលនៃថ្ងៃសវនាការនីមួយៗ ក៏ដូចជាលទ្ធភាពអាចចូលរួមបានរបស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បន្ថែមទៀតទៅនឹងក្ដីកង្វល់របស់ខ្លួនមកកាន់ការិយាល័យរដ្ឋបាល ទាក់ទងនឹងការបកប្រែភាសាផ្ទាល់មាត់ និងការបកប្រែឯកសារ និងការពន្យារពេលដែលអាចមាន ប្រសិនបើកង្វល់ទាំងនេះមិនត្រូវបានដោះស្រាយ។ ការិយាល័យរដ្ឋបាលបានចាត់វិធានការដោះស្រាយបញ្ហានេះ និងបន្តត្រួតពិនិត្យបញ្ហានេះតាមករណីជាក់ស្ដែងនីមួយៗ។

### ខ. បទចោទដែលនៅសេសសល់/ការចោទប្រកាន់តាមអង្គហេតុក្នុងសំណុំរឿង០០២

៣៩. នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ អង្គជំនុំជម្រះតុលាការកំពូលប្រកាសផ្អាកដំណើរការនីតិវិធីពាក់ព័ន្ធនឹងបទចោទដែលនៅសល់ ដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ និង ០០២/០២ ដោយរង់ចាំសេចក្ដីសម្រេចសមស្របរបស់អង្គជំនុំជម្រះសាលាដំបូង[9]។ អង្គជំនុំជម្រះតុលាការកំពូលលើកឡើងម្ដងទៀតថា អង្គជំនុំជម្រះសាលាដំបូងមានករណីកិច្ចកាត់សេចក្ដី ឬចេញសេចក្ដីសម្រេចទៅលើបទចោទដែលនៅសល់ក្នុងសំណុំរឿង០០២ អនុលោមតាមក្រមខណ្ឌគតិយុត្ត និងជំរុញឲ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តទៅតាមករណីកិច្ចនេះ។ មកដល់ពេលនេះ អង្គជំនុំជម្រះពុំទាន់បានទទួលសំណើណាមួយទាក់ទិននឹងបញ្ហានេះទេ។ បញ្ហានេះនៅតែស្ថិតក្នុងការពិចារណាដដែល។

### គ. សំណុំរឿង០០៣ និង សំណុំរឿង០០៤

៤០. លុះត្រាតែមានសេចក្ដីសម្រេចថាតើ សំណុំរឿង០០៣ និង/ឬ០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ ទើបអាចធ្វើការស្មានទុកបានទៅលើរយៈពេលសម្រាប់បញ្ចប់ការជំនុំជម្រះក្ដីទាំងនេះបាន។ ការវាយតម្លៃលើពេលវេលាដែលតម្រូវ អាចផ្អែកទៅលើចំនួនចុងចោទ ក៏ដូចជាចំនួន និងភាពស្មុគស្មាញនៃអង្គហេតុ និងអង្គច្បាប់នៃបទចោទ និងទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## V. ផែនការបញ្ចប់បណ្ដឹងសាទុក្ខ

៤១. ដើម្បីធ្វើការប៉ាន់ស្មានអំពីរយៈពេលសម្រាប់ដំណើរការនីតិវិធីបណ្ដឹងសាទុក្ខ ត្រូវតែញែកឲ្យបានច្បាស់អំពីដំណាក់កាលបណ្ដឹងសាទុក្ខសំខាន់ៗ ដូចតទៅ ៖ ដំណាក់កាលទីមួយ គឺត្រូវការពេលវេលាសម្រាប់ដាក់សារណារបស់ភាគីទាំងអស់។ អនុលោមតាមវិធានផ្ទៃក្នុង ភាគីត្រូវដាក់សេចក្ដីជូនដំណឹងពីបណ្ដឹងសាទុក្ខក្នុងរយៈពេល៣០ថ្ងៃ ក្រោយពីការប្រកាសសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ក្នុងករណីដែលមានបណ្ដឹងសាទុក្ខដោយភាគីណាមួយ ភាគីដទៃទៀតមានរយៈពេលបន្ថែម១៥ថ្ងៃទៀត ដើម្បីដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ។ វិធានផ្ទៃក្នុងចែងថាម្ចាស់បណ្ដឹងសាទុក្ខត្រូវដាក់ជូនសារណាបណ្ដឹងសាទុក្ខក្នុងរយៈពេល៦០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងពីការប្ដឹងសាទុក្ខ។ ភាគីនឹងមានរយៈពេល១០ថ្ងៃក្នុងការដាក់ចម្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់ភាគីដទៃទៀត។ ប៉ុន្តែកាលពីពេលកន្លងទៅ អង្គជំនុំជម្រះបានផ្ដល់ជូនរយៈពេលបន្ថែមសមរម្យសម្រាប់ដាក់ចម្លើយតប។ ក្នុងអំឡុងពេលនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងស្រាវជ្រាវទៅលើបញ្ហាច្បាប់ និងអង្គហេតុដែលពាក់ព័ន្ធ ដើម្បីរៀបចំខ្លួនពេញលេញសម្រាប់សវនាការលើបណ្ដឹងសាទុក្ខដែលជាដំណាក់កាលទីពីរ។ ស្ថិតក្នុងលក្ខខណ្ឌជាក់លាក់ ភាគីក៏មានសិទ្ធិស្នើសុំស្ដាប់សវនាការលើភស្ដុតាងបន្ថែមលើបណ្ដឹងសាទុក្ខ ដែលអាចតម្រូវឱ្យអង្គជំនុំជម្រះតុលាការកំពូលរៀបចំកាលវិភាគសវនាការលើភស្ដុតាង។ សវនាការលើបណ្ដឹងសាទុក្ខអាចត្រូវបានបង្គាប់ នៅពេលណាភាគីបានដាក់សារណាទាំងអស់របស់ខ្លួន និងពិនិត្យដោយអង្គជំនុំជម្រះតុលាការកំពូលរួចហើយសិន ហើយសំណើណាមួយស្នើសុំភស្ដុតាង

[9] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមនៃសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ E301/9/1/13 ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤។

បន្ថែមត្រូវបានសម្រេច។ ដំណាក់កាលទីបី គឺការពិភាក្សាសម្រេចក្រោយពេលសវនាការនោះ និងការរៀបចំចេញសាលដីកាលើបណ្ដឹងសាទុក្ខ។

### ក. សំណុំរឿង០០២/០១

៤២. តាមសំណើរបស់ក្រុមមេធាវីការពារក្ដី ដោយផ្អែកលើទំហំនិងភាពស្មុគស្មាញនៃរឿងក្ដី និងសាលក្រម អង្គជំនុំជម្រះតុលាការកំពូលបានពន្យារពេលកំណត់ដាក់ការជូនដំណឹងរបស់ក្រុមមេធាវីការពារក្ដីអំពីបណ្ដឹងសាទុក្ខលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០១ ក៏ដូចជាកាលបរិច្ឆេទកំណត់ និងចំនួនទំព័រកំណត់សម្រាប់ការដាក់សារណាបណ្ដឹងសាទុក្ខ ដែលត្រូវបានអនុញ្ញាតឱ្យដាក់ជាបឋមជាភាសាបារាំង ឬអង់គ្លេស ដោយដាក់សំណៅបកប្រែជាភាសាខ្មែរតាមក្រោយ។

៤៣. ក្រុមមេធាវីការពារក្ដី នួន ជា និង ខៀវ សំផន បានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ខ្លួននៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ និងសារណាបណ្ដឹងសាទុក្ខរបស់ខ្លួននៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ដោយមូលដ្ឋានបណ្ដឹងសាទុក្ខរបស់ខ្លួនមានចំនួន ២២៣ សម្រាប់ នួន ជា និង ១៥៨ សម្រាប់ ខៀវ សំផន ដែលគ្របដណ្ដប់លើស្ទើរតែការរកឃើញទាំងអស់ក្នុងសាលក្រមសំណុំរឿង ០០២/០១ ព្រមទាំងលើសេចក្ដីសម្រេចជាច្រើនរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមិនអនុញ្ញាតបើកផ្លូវប្ដឹងសាទុក្ខភ្លាមៗ រហូតទាល់តែចេញសាលក្រមលើអង្គសេចក្ដី[10]។ លើសនេះទៀត សហព្រះរាជអាជ្ញាបានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ដែលកំហិតត្រឹមតែការស្នើសុំការប្រកាសពីអង្គជំនុំជម្រះតុលាការកំពូល ទាក់ទងនឹងភាពអាចអនុវត្តបាននៃទម្រង់ពង្រីកបំផុតនៃសហឧក្រិដ្ឋកម្មរួម ដែលគេស្គាល់ថា “JCE III” នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ សារណាតបទៅនឹងបណ្ដឹងសាទុក្ខនេះត្រូវបានដាក់ដោយសហព្រះរាជអាជ្ញានៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤។

៤៤. ការបកប្រែឯកសារជាភាសាខ្មែរនៃចម្លើយតបរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី តបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី ត្រូវបានបញ្ចប់ក្នុងខែសីហា និងខែកក្កដា ឆ្នាំ២០១៥ តាមលំដាប់។ សវនាការលើអង្គសេចក្ដីនៃបណ្ដឹងសាទុក្ខនេះមិនអាចកំណត់កាលវិភាគបាននៅឡើយទេ រហូតទាល់តែសារណា និងចម្លើយតបទាំងអស់មានជាភាសាខ្មែរ និងអង់គ្លេស ឬបារាំង ។ ហេតុដូច្នេះ កត្តាមួយផ្សេងទៀតដែលកំពុងប៉ះពាល់យ៉ាងសំខាន់ដល់រយៈពេលនៃកិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខគឺពិតជាអាស្រ័យលើលទ្ធភាពនៃការបកប្រែសារណាបណ្ដឹងសាទុក្ខ ជាពិសេសពីភាសាអង់គ្លេសទៅភាសាខ្មែរ។

៤៥. បន្ថែមលើការដាក់ឯកសារសំខាន់ៗលើបណ្ដឹងសាទុក្ខ ការប៉ាន់ស្មានផ្អែកលើអង្គហេតុដែលថាមេធាវីការពារក្ដី នួន ជា បានអនុវត្តសិទ្ធិនីតិវិធីយ៉ាងទូលំទូលាយដែលគាត់មាន និងបានដាក់ញត្តិដាច់ដោយឡែកចំនួនប្រាំមួយស្នើសុំភស្ដុតាងបន្ថែមនៅដំណាក់កាលបណ្ដឹងសាទុក្ខ ចាប់តាំងពីការចេញសាលក្រមសំណុំរឿង ០០២/០១។ ញត្តិទាំងអស់នេះ ដែលញត្តិចុងក្រោយបានដាក់នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ភាគច្រើនជាលទ្ធផលមកពីការដាក់បង្ហាញភស្ដុតាងជាបន្តបន្ទាប់ ដែលត្រូវបានធ្វើនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និងមកពីសវនាការជាបន្តបន្ទាប់លើភស្ដុតាងក្នុងសំណុំរឿង០០២/០២ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ញត្តិបន្ថែមទៀតស្នើសុំភស្ដុតាងបន្ថែមនឹងនៅតែអាចត្រូវបានដាក់ ដែលអាចនាំឱ្យមានផលប៉ះពាល់លើតារាងពេលវេលាសម្រាប់ការសម្រេចលើបណ្ដឹងសាទុក្ខ។ ជាលទ្ធផលនៃសំណើស្នើសុំភស្ដុតាងបន្ថែមទាំងអស់នេះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេច*ជាអាទិ៍* ឱ្យដាក់ចេញនូវការស៊ើបអង្កេតបន្ថែមដ៏មានកម្រិត ក៏ដូចជាក្នុងការកោះហៅសាក្សីបីរូបនៅពេលបណ្ដឹងសាទុក្ខ។ សវនាការទាក់ទងនឹងសាក្សីទាំងបីនេះត្រូវបានធ្វើឡើងពីថ្ងៃទី២ ដល់ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៥។ ការស៊ើបអង្កេតបន្ថែមត្រូវបានបិទបញ្ចប់នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥ នៅ

---

[10] សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ ឯកសារ E313/1/1 ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤។ សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ E313/1/1 ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤។

ពេលដែលអង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចលើសំណើសុំភ័ស្តុតាងបន្ថែមទាំងអស់ដែលនៅសេសសល់។

៤៦. ការកត់សម្គាល់ជាក់លាក់ គប្បីត្រូវបានធ្វើឡើងចំពោះកាលៈទេសៈពិសេសរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការដោះស្រាយសេចក្តីសម្រេចជាច្រើន ភាគច្រើនផ្នែកនីតិវិធី ដែលបានធ្វើឡើងក្នុងអំឡុងពេលកិច្ចដំណើរការជំនុំជម្រះ ដែលអាចប្តឹងសាទុក្ខបានតែក្រោយពេលចេញសាលក្រមសាលាដំបូងប៉ុណ្ណោះ។ ចំណុចនេះខុសពីស្ថានភាពនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ឬនៅសាលាក្តី*មិនអចិន្ត្រៃយ៍*នានា ដែលអាចស្នើសុំដាក់បណ្តឹងសាទុក្ខបន្ទាន់បន្ទំចំពោះសេចក្តីសម្រេចបែបអស់ទាំងនោះ ពោលគឺ ខណៈពេលកំពុងធ្វើការជំនុំជម្រះ ដើម្បីដោះស្រាយបញ្ហាចម្រូងចម្រាសនានាដែលកើតមានឡើង។ យ៉ាងណាមិញ យោងតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង អ.វ.ត.ក. យុត្តាធិការបណ្តឹងសាទុក្ខក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះគឺមានកម្រិតតិចតួចបំផុត។ ហេតុដូច្នេះ បន្ទាប់ពីការវិភាគលើសារណាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២ វាបង្ហាញយ៉ាងច្បាស់ថាពេលនេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវលះបង់ពេលរបស់ខ្លួនប្រមាណ ៥០% ដើម្បីពិនិត្យបញ្ហានានា ដែលនៅតុលាការ ICC ឬសាលាក្តី *មិនអចិន្ត្រៃយ៍* អាចបានដោះស្រាយតាំងពីមុនពេលបណ្តឹងសាទុក្ខម្ល៉េះ។

៤៧. ដោយពិចារណាលើកត្តាទាំងអស់នេះ និងបទពិសោធន៍ពីតុលាការ និងសាលាក្តីអន្តរជាតិ និង អន្តរជាតូបនីយកម្មផ្សេងទៀត ដែលសំណុំរឿងមានទំហំនិងភាពស្មុគស្មាញប្រហាក់ប្រហែលគ្នា ហេតុនេះ ការប៉ាន់ស្មានល្អបំផុតដែលអាចផ្តល់ជូននាពេលនេះគឺថា ដំណើរការបណ្តឹងសាទុក្ខអាចនឹងត្រូវបញ្ចប់យ៉ាងឆាប់បំផុតនៅចុងត្រីមាសទីពីរ ឆ្នាំ២០១៦។ បញ្ហាលំបាកដែលមិនអាចប្រមើលដឹងជាមុនបានកើតឡើងនៅសវនាការបណ្តឹងសាទុក្ខ ដែលអង្គជំនុំជម្រះតុលាការកំពូលបានគ្រោងធ្វើពីថ្ងៃទី១៧ ដល់១៩ ខែវិច្ឆិកា ឆ្នាំ២០១៥ ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលគ្មានជម្រើសអ្វីក្រៅពីផ្អាកសវនាការនៅថ្ងៃដំបូង។ មូលហេតុដោយសារមិនមានតំណាងផ្នែកច្បាប់ត្រឹមត្រូវសម្រាប់ នួន ជា ដោយសារតែមេធាវីដែលត្រូវបានតែងតាំងសម្រាប់ នួន ជា ដោយអះអាងថាអនុវត្តតាមការណែនាំរបស់ជនជាប់ចោទ បានពហិការមិនចូលរួមសវនាការ ដែលខកខានមិនបានចូលរួមពេញលេញក្នុងវគ្គសវនាការ។ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយបញ្ហានេះ ដោយតែងតាំងមេធាវីប្រចាំការសម្រាប់ នួន ជា ដើម្បីធានាថាកិច្ចដំណើរការនីតិវិធីអាចបន្តដោយគ្មានការរាំងស្ទះ បើទោះជាមានការប្រព្រឹត្តិណាមួយនាពេលខាងមុខរបស់មេធាវីការពារក្តី នួន ជា បច្ចុប្បន្នក្តី។ បន្ទាប់ពីការតែងតាំងមេធាវីប្រចាំការនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ និងបន្ទាប់ពីពិចារណាលើតម្រូវការផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់គាត់ត្រៀមរៀបចំនោះ អង្គជំនុំជម្រះតុលាការកំពូលបានគ្រោងបន្តសវនាការបណ្តឹងសាទុក្ខឡើងវិញនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៦។

៤៨. ចំពោះជំហានបន្ទាប់ក្នុងដំណើរការបណ្តឹងសាទុក្ខ ខែបន្ទាប់ៗនឹងមានការពិនិត្យបន្ថែមទៀតលើការដាក់ឯកសារទាំងអស់ ការធ្វើឯកសារត្រៀមរៀបចំ និងការធ្វើសវនាការបណ្តឹងសាទុក្ខ។ បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូលនឹងបញ្ចប់ការប្រជុំពិភាក្សា និងរៀបចំចេញសាលដីការបស់ខ្លួនក្នុងសំណុំរឿង ០០២/០១។

### ខ. សំណុំរឿង ០០២/០២

៤៩. សម្រាប់សំណុំរឿង០០២/០២ ដោយផ្អែកលើការព្យាករណ៍បច្ចុប្បន្នរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាការជំនុំជម្រះដំណាក់កាលទីពីរទំនងជានឹងមានលក្ខណៈស្មុគស្មាញ និងត្រូវការពេលវេលាច្រើនដូចជាការជំនុំជម្រះដំណាក់កាលទីមួយនោះ អង្គជំនុំជម្រះតុលាការកំពូលក៏ព្យាករស្រដៀងគ្នានេះដែរនៅពេលនេះដែលថាបណ្តឹងសាទុក្ខ(ទាំងឡាយ)ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះក្នុងសំណុំរឿង០០២/០២ នឹងមានលក្ខណៈស្មុគស្មាញ និងត្រូវការពេលវេលាច្រើន ដូចគ្នានឹងបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង០០២/០១ ហើយកត្តានានា ដូចជាសំណើសុំពន្យារពេលក្នុងការដាក់សារណា ឬញត្តិ ដើម្បីស្នើដាក់ជូនភ័ស្តុតាងបន្ថែម អាចប៉ះ

ពាល់ដល់រយៈពេលនៃដំណើរការនីតិវិធីបណ្តឹងសាទុក្ខ។ ទំហំការងារបែបនេះនឹងត្រូវការគិតបញ្ចូលទៅក្នុងការរៀបចំផែនការក្រោយពេលមានការដាក់បណ្តឹងសាទុក្ខ។

៥០. សម្រាប់ពេលបច្ចុប្បន្ននេះ ដោយកត់សម្គាល់លើការបន្ថែមពេលលើតារាងពេលវេលារបស់អង្គជំនុំជម្រះសាលាដំបូង សម្រាប់ការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ រយៈពេលបីខែបន្ថែមទៀត ដូច្នេះអង្គជំនុំជម្រះតុលាការកំពូលធ្វើការប៉ាន់ស្មាននូវពេលវេលាបន្ថែមដូចគ្នានេះ ទៅលើការបញ្ចប់បណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២។

៥១. ជាងនេះទៅទៀត បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០២ ត្រូវតែសម្រេចក្នុងរយៈពេលបីខែជាកំណត់។ ផ្អែកលើបទពិសោធន៍ពីសំណុំរឿង ០០២/០១ ដែលគិតជាមធ្យមមានបណ្តឹងសាទុក្ខភ្លាមៗចំនួនមួយផងដែរក្នុងមួយខែត្រូវបានដាក់ រំពឹងថានឹងមានបណ្តឹងសាទុក្ខភ្លាមៗជាច្រើន ចេញមកពីកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង០០២/០២ ផងដែរ។ ប្រការនេះអាចធ្វើឲ្យមានតម្រូវការធនធានរបស់អង្គជំនុំជម្រះតុលាការកំពូលកាន់តែច្រើនឡើង ហើយប៉ះពាល់ដល់តារាងកំណត់ពេលវេលាសម្រាប់ការចេញសាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១។

## VI. សេចក្តីសន្និដ្ឋាន

៥២. សម្រាប់ឆ្នាំ២០១៦ យើងរំពឹងថានឹងសម្រេចបាននូវគ្រោងការសំខាន់ៗចំនួនពីរ ក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ គឺ៖ (i) ការចេញសាលដីកាក្នុងសំណុំរឿង ០០២/០១ និង (ii) ការបញ្ចប់សវនាការលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២។ ចំពោះសំណុំរឿង ០០៣ និង ០០៤ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការសំខាន់ៗចំនួនបួនគឺ៖ (i) ការជូនដំណឹងអំពីការបិទបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ (ii) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ ជាមួយនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតថាតើត្រូវបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីតែម្តង (iii) ការជូនដំណឹងអំពីការបិទបញ្ចប់កិច្ចស៊ើបសួរសម្រាប់ការចោទប្រកាន់ដែលនៅសល់ក្នុងសំណុំរឿង ០០៤ និង (iv) ការចេញដីកាដំណោះស្រាយពីរក្នុងសំណុំរឿង០០៤ ជាមួយនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតថាតើត្រូវបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីតែម្តង។

៥៣. សម្រាប់ឆ្នាំ២០១៧ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការចំនួនបី ក្នុងសំណុំរឿង០០២/០២ ពោលគឺ៖ (i) ការចេញសេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោល (ii) ការចេញសាលក្រម និង (iii) កាលបរិច្ឆេទចុងក្រោយក្នុងការដាក់ការជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម។ ក្នុងសំណុំរឿង ០០៣ និង ០០៤ រំពឹងថានឹងសម្រេចបានគ្រោងការសំខាន់ចំនួនបីបន្ថែមទៀតគឺ៖ (i) ការសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ (ii) ការចេញដីកាដំណោះស្រាយមួយក្នុងសំណុំរឿង ០០៤ និង (iii) ការសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយមួយ(ច្រើន) ក្នុងសំណុំរឿង ០០៤ ជាមួយនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ថាតើត្រូវបញ្ជូនសំណុំរឿងទាំងនេះទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី។ ក្នុងករណីដែលសំណុំរឿងណាមួយ ឬសំណុំរឿងទាំងពីរ ត្រូវបានបញ្ជូនទៅជំនុំជម្រះទាំងមូល ឬដោយផ្នែក ការព្យាករណ៍ទុកនូវតារាងកំណត់ពេលវេលាក្នុងសំណុំរឿងទាំងនេះ គឺអាចយកមកវាយតម្លៃបាន។

៥៤. ក្នុងអំឡុងឆ្នាំ២០១៨ អង្គជំនុំជម្រះតុលាការកំពូលនឹងជាប់រវល់ធ្វើសវនាការបណ្តឹងសាទុក្ខ និងការពិភាក្សាសម្រេច ក្នុងករណីដែលមានបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។

៥៥. សម្រាប់ឆ្នាំ២០១៩ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការសំខាន់មួយគឺ ការចេញសាលដីកាលើសំណុំរឿង០០២/០២។

៥៦. ការស្មានទុកនូវគ្រោងការសំខាន់ៗនានាដែលរៀបរាប់ខាងលើនេះ មានសង្ខេបជូនក្នុងតារាងដែលភ្ជាប់ជាមួយនឹងផែនការនេះស្រាប់។

# តារាងកំណត់ពេលវេលាតាមការគ្រោងទុកសម្រាប់ការបញ្ចប់ផែនការ ដែលរួមមានគ្រោងការសំខាន់ៗ




(ក) កាលបរិច្ឆេទកំណត់សម្រាប់ចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខ

(ខ) សវនាការលើបណ្តឹងសាទុក្ខ




(គ) ការបញ្ចប់សវនាការលើភស្តុតាង

(ឃ) សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល

(ង) សាលក្រម

(ច) កាលបរិច្ឆេទកំណត់សម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម

(ឆ) សាលដីកា




(ជ) ការជូនដំណឹងអំពីការបញ្ចប់ការស៊ើបអង្កេត

(ឈ) ដីកាដំណោះស្រាយ ក.ស.ច.ស.

(ញ) សេចក្តីសម្រេចរបស់ អ.ប.ជ. ទៅលើដីកាដំណោះស្រាយ




ប្រសិនបើបំបែក

ប្រសិនបើបំបែក

ប្រសិនបើបំបែក

(ដ) ការជូនដំណឹងអំពីការបញ្ចប់ការស៊ើបអង្កេត។ ពេលវេលាកំណត់អាស្រ័យទៅលើថាតើ សំណុំរឿងនឹងត្រូវបានបំបែក ឬទេ។
(ឋ) ដីកាដំណោះស្រាយ ក.ស.ច.ស.។ ពេលវេលាកំណត់អាស្រ័យទៅលើ សំណុំរឿងនឹងត្រូវបានបំបែក ឬទេ។
(ឌ) ដីកាដំណោះស្រាយ អ.ប.ជ.